គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) សូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់ឲ្យបានជ្រាបថា ខុមហ្វ្រែល នឹងរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់បណ្តាញខុមហ្វ្រែល អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ស្តីពី″ **វិធីសាស្ត្រក្នុងការសង្កេតការឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត**″ ចាប់ពីថ្ងៃទី២០ ដល់២៣ ខែឧសភា ឆ្នាំ២០១៣។ វគ្គបណ្តុះបណ្តាលនេះ នឹងរៀបចំនៅមជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ ជិតសារៈមន្ទីរទួលស្លែង ដែលមានអ្នកចូលរួមប្រមាណជិត១០០នាក់ មកពីបណ្តាញខុមហ្វ្រែលនៅ២៣ខេត្ត/រាជធានី អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ។

គោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលគឺ ដើម្បីឲ្យអ្នកសង្កេតការណ៍ខុមហ្វ្រែល តំណាងគណបក្សនយោបាយ និងតំណាងសង្គមស៊ីវិល មានជំនាញក្នុងការសង្កេតការណ៍បោះឆ្នោត និងក្លាយជាគ្រូបង្គោលដើម្បីបង្រៀនបន្តដល់ អ្នកសង្កេតការណ៍ផ្សេងទៀត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដែលនឹងឈានមកដល់នាពេលខាងមុខនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអញ្ជើញលោក លោកស្រី តំណាងសារព័ត៌មានជាតិ និងអន្តរជាតិ ចូលរួមយកព័ត៌មានតាមការគួរ។

**ព័ត៌មានបន្ថែម សូមទំនាក់ទំនង**

កញ្ញា គង់ រ៉ាវីន អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ០១២ ៦៥ ៤៩ ៥០

លោក ស៊ិន ទិត្យសីហា មន្ត្រីផ្នែកអង្កេតខុមហ្វ្រែល ០១២ ២៥២ ៦៦១

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.